**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិថ្មី
# រយៈពេល ៣ឆ្នាំ ( កក្កដា ២០២៥ - មិថុនា ២០២៨ )

**ឈ្មោះសហគមន៍នេសាទ ៖ ភូមិថ្មី**
ភូមិ ៖ ភូមិថ្មី
សង្កាត់ ៖ ព្រៃធំ
ក្រុង ៖ កែប
ខេត្ត ៖ កែប

រៀបចំដោយរដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផលកែប (គម្រោងជលផលសមុទ្រនិងតំបន់ឆ្នេរប្រកបដោយចីរភាព)

# មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**.....១
**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**.....២
ក- ប្រជាពលរដ្ឋ.....២
ខ- មុខរបរ.....៣
**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**.....៣
ក- ទីតាំង.....៣
ខ- ដែននេសាទ.....៣
គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស.....៣
ឃ- ធនធានជលផល.....៤
**៤- ការធ្វើនេសាទ**.....៤
ក- អ្នកនេសាទ.....៤
ខ- ឧបករណ៍នេសាទ.....៤
គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ.....៦
**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**.....៧
**ក- ទស្សនៈវិស័យ**.....៧
**ខ- គោលបំណង**.....៧
**គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**.....៧
**ផ្នែកទី១.ការអភិបាលកិច្ចនិងការគ្រប់គ្រង**.....៧
គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.....៧
គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ.....៨
គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល.....៨
គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ.....៩
គ៥- ផែនការទប់ស្កាត់បទល្មើសជលផល.....១០
គ៦- ផែនការកែលម្អកន្លែងនេសាទសហគមន៍.....១១
គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.....១២
គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ.....១២
គ៩- ផែនការគ្រប់គ្រងព្រៃកោកាង.....១៣
**ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ**.....១៤
គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.....១៤
គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ.....១៥
គ១២- ផែនការបង្កើតកន្លែងទេសចរណ៍ធម្មជាតិរបស់សហគមន៍នេសាទ.....១៦
គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ.....១៧
ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**.....១៨
គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ.....១៨
គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ.....១៨

**ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន**........................................១៩

គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន........................................១៩

គ១៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍........................................២០

**ឃ- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**........................................២០

**ង. ផែនការយុទ្ធសាស្រ្ត**........................................២១

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិថ្មី រយៈពេល៣ឆ្នាំ**........................................២២

**តារាងពេលវេលាការងារ**........................................២៩

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិថ្មី ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១១ បន្ទាប់មកបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រកាសលេខ ១៤០ ប្រក.កសក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣។ សហគមន៍នេសាទនេះ បានរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការជាថ្មីទៅតាមលក្ខខន្តិកៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ដោយមានគណៈកម្មការចំនួន៩នាក់ ស្រី២នាក់ និងមានក្រុមល្បាតចំនួន៧នាក់។ ចំពោះសមាជិកសហគមន៍កន្លងមកសហគមន៍នេសាទភូមិថ្មី សរុបចំនួន១១០នាក់ ស្រី៦០នាក់ ត្រូវនឹង១១០គ្រួសារ ហើយនាពេលបច្ចុប្បន្នសមាជិកសហគមន៍នេសាទកើនបានសរុបចំនួន១៦៣នាក់ ស្រី១០០នាក់។

កន្លងមកសហគមន៍នេសាទភូមិថ្មី បានរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដោយបានកំណត់ព្រំប្រទល់ផែនទីកន្លែងនេសាទសហគមន៍ ព្រមទាំងរចនាសម្ព័ន្ធគ្រប់គ្រងដែលបានបែងចែកតួនាទី និងភារកិច្ចការទទួលខុសត្រូវ របស់គណៈកម្មការ និងសមាជិកសហគន៍ដែលមានការទទួលស្គាល់ឯកភាពពីភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិនិងអាជ្ញាធរមូលដ្ឋាន។ ចំពោះផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គណៈកម្មការនិងសមាជិកសហគមន៍សហការជាមួយដៃគូពាក់ព័ន្ធ បានអនុវត្តសកម្មភាពសំខាន់ៗ រួមមាន ចូលរួមប្រជុំនិងបិទផ្សាយផែនទីកន្លែងនេសាទសហគមន៍ រៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ បង្កើតធនាគារក្តាមសេះ ដើម្បីបង្កើនផលស្តុកក្តាមសេះក្នុងធម្មជាតិ ផ្តួចផ្តើមសកម្មភាពមុខរបរ តាមរយៈសេវាកម្មកសិទេសចរណ៍សហគមន៍ ចូលរួមយុទ្ធនាការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពនានា រៀបចំក្រុមល្បាតសហគមន៍និងចុះល្បាតដោយសហការជាមួយសមត្ថកិច្ចជលផល អាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់ និងបង្រ្កាបបទល្មើសនេសាទកើតមានក្នុងកន្លែងនេសាទសហគមន៍។ សកម្មភាពទាំងនេះសបញ្ជាក់ពីការប្រឹងប្រែងអនុវត្តសកម្មភាពមានចែងក្នុងផែនការគ្រប់គ្រងរបស់ខ្លួន ទៅតាមធនធានដែលមានកំណត់។ បច្ចុប្បន្នសហគមន៍នេសាទភូមិថ្មីកំពុងខិតខំគៀងគរការចូលរួមធនធាននិងការគាំទ្រនានាដើម្បីដោះស្រាយបញ្ហាប្រឈមដែលនៅតែកើតមានឡើងដូចខាងក្រោម៖

- ផលនេសាទថយចុះបណ្តាលពីរសកម្មភាពនេសាទលើសកម្រិត ដោយតម្រូវការកើនឡើង ការប្រើឧបករណ៍នេសាទបំផ្លិចបំផ្លាញមានដូចជា ការនេសាទដោយប្រើប្រាស់ស្បៃមុង ទូកអូសនៅទឹករាក់ ការប្រើប្រាស់ឧបករណ៍ឆក់ជាដើម។
- ការថយចុះប្រព័ន្ធអេកូស៊ីស្ទែមជលផលសមុទ្រដូចជា ជម្រកជលផលសមុទ្រ ព្រៃកោងកាង ស្មៅសមុទ្រដែលកំពុងរងផលប៉ះពាល់ពីការនេសាទបានបំផ្លិចបំផ្លាញ។
- សមត្ថភាពនិងចំណេះដឹងរបស់គណៈកម្មការនិងសមាជិកនៅមានកម្រិតដូចជា ខ្វះជំនាញបច្ចេកទេសលើការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាពនិងការអនុវត្តការងារគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋានឬសហគ្រប់គ្រងនៅមានកម្រិត

- ធ្វើអោយការជ្រើសរើសមុខរបរសម្រាប់ទ្រទ្រង់សមាជិកសហគមន៍នេសាទនិងងាយរងគ្រោះ ដោយពឹងផ្អែកលើប្រភពចំណូលតែមួយ និងផលចាប់ពីធម្មជាតិ អស្ថេរភាពតម្លៃផលិតផល កំណត់ដោយឈ្មួញកណ្តាលក្នុងតំបន់ពិបាកក្នុងការទទួលបាន តម្លៃបន្ថែមលើផលិតផលដោយសារគុណភាពផលិតផលនិងការកែច្នៃ ខ្វះទុនក្នុងការចាប់ផ្តើម និងជំនាញលើមុខរបរ ដូចជាការបង្កើនសេវាកសិទេសចរណ៍ វារីវប្បកម្ម ដែលមិនប្រើចំណីជាដើម
- ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិប៉ះពាល់ដល់ការប្រកបរបរនេសាទធ្វើអោយប៉ះពាល់កំណើនជាតិពុលក្នុងទឹក កំដៅទឹកសមុទ្រប៉ះពាល់ដល់ទេសចរណ៍ និងការវារីវប្បកម្ម
- ការបំពុល ការចោលសំរាម និងផ្លាស្ទិច បណ្តាលពីការបង្ហូរកាកសំណល់នានាធ្វើអោយប៉ះពាល់គុណភាព ទឹកសមុទ្របង្កឱ្យមានជាតិពុល
- សម្តភាពរបស់គណៈកម្មការសហគមន៍នេសាទនៅមានកម្រិត ដូចជា ការងាររដ្ឋបាល ការអនុវត្តសកម្មភាព ការងារគ្រប់គ្រង ការងារសេដ្ឋកិច្ច ការការពារធនធានជលផល និងសកម្មភាពការងារល្បាត
- ពង្រឹងក្នុងការអនុវត្តច្បាប់មានកម្រិត ដោយខ្វះមធ្យោបាយ ដូចជាឧករណ៍ទំនាក់ទំនងរាយការណ៍ ទូកល្បាតដែលធននឹងអាកាសធាតុ ប្រភពថវិកាគាំទ្រសកម្មភាពល្បាត ការចូលរួមពីសមាជិកមានកម្រិត ការផ្សព្វផ្សាយច្បាប់ស្តីពី ជលផលមិនមានលទ្ធភាពចូលរួមក្នុងការអនុវត្ត។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិថ្មី ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៧ លេខ១១៥២ ជផ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤ ត្រូវរៀបចំកែសម្រួលឡើងវិញ ដោយធ្វើបច្ចុប្បន្នភាពនូវទិន្នន័យសហគមន៍នេសាទ សកម្មភាពនានាស្របនឹងនិន្នាការថ្មីៗ តម្រូវការសហគមន៍ និងការប៉ាន់ប្រមាណថវិកា ដោយផ្តោតលើការអភិរក្សជលផល ការបង្កើតមុខរបរ ការគ្រប់គ្រងសកម្មភាពនេសាទ និងការប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍នេសាទប្រកបដោយនិរន្តរភាព និងការចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ស្របតាមប្រការ៣០ នៃប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំសហគមន៍នេសាទ។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

ប្រជាពលរដ្ឋសរុបក្នុងតំបន់មានចំនួន ៣ ១៥០ នាក់ ស្រី ១ ៩៨៧ នាក់ ក្នុងនោះមានចំនួន ៦៣០ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ៥០% និងកាន់សាសនាឥស្លាម ៥០%។

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរ៥នាក់ស្រី២នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន២៥៣នាក់ ស្រី១៩៣នាក់ និងកម្រិតវិទ្យាល័យចំនួន៧៩នាក់ ស្រីចំនួន២៣នាក់ ។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១១៦នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន២នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន២៣នាក់ ស្រី១២នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន២៥នាក់ ស្រី១១នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន១៥នាក់ ស្រី៧នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន២នាក់ ស្រី២នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទ ចំនួន ១៤៥ គ្រួសារ
- ធ្វើស្រែ ចំនួន ១៧៥ គ្រួសារ ទំហំ៧៥ ហិកតា
- ធ្វើចំការ ចំនួន១០ គ្រួសារ ទំហំ០,៣-០,៨ហិកតា
- ដាំបន្លែ ចំនួន ២០ គ្រួសារ
- ចិញ្ចឹមសត្វ ចំនួន៥៨គ្រួសារ
- ធ្វើវារីវប្បកម្ម ចំនួន ៧ គ្រួសារ
- ជាងផ្ទះ ចំនួន ៣ គ្រួសារ
- លក់ដូរ ចំនួន ៧៥ គ្រួសារ
- កម្មករ ចំនួន១១៥ គ្រួសារ
- ធ្វើសិប្បកម្ម ចំនួន១ គ្រួសារ (បង្គាក្រៀម និងគី)
- លក់ដូរវត្ថុអនុស្សាវរីយ៍ចំនួន៣គ្រួសារ។

ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៩ ៦០០ ០០០ រៀល ។

## ៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍ភូមិថ្មី ជាដែននេសាទសមុទ្រ មានកន្លែងនេសាទតាមឆ្នេរ កន្លែងអភិរក្សជលផល ស្មៅសមុទ្រ នាទីព្រៃកោងកាង វាលភក់ ដែលជាដែននេសាទសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។ សហគមន៍នេសាទភូមិថ្មី មានទំហំ **១៩៨** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។

សហគមន៍នេសាទភូមិថ្មី មានព្រំប្រទល់ ៖

- ខាងជើងជាប់នឹងកន្លែងសហគមន៍នេសាទកំពង់ត្រឡាច
- ខាងត្បូងជាប់នឹងផ្លូវបេតុងឆ្នេរខ្សាច់ (ឆ្នេរតេជោសន្តិភាពកែប)
- ខាងកើតជាប់នឹងផ្លូវលំ ព្រំព្រៃកោងកាង ភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប
- ខាងលិចជាប់នឹងសមុទ្រ។

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍ភូមិថ្មី មានលំហសមុទ្រចំនួន១ វាលភក់ចំនួន១ និងនាទីព្រៃកោងកាងចំនួន១ គឺ៖

- លំហសមុទ្រ ទំហំ ១៧៣,៨ ហិកតា នេសាទពេញមួយឆ្នាំ
- វាលភក់ ទំហំ ១៤,២ ហិកតា នេសាទពេញមួយឆ្នាំ
- នាទីព្រៃកោងកាង ទំហំ ១០ ហិកតា នេសាទពេញមួយឆ្នាំ ។

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល**

សហគមន៍នេសាទភូមិថ្មី បានសម្រេចបង្កើតកន្លែងអភិរក្សជលផលមួយកន្លែងមានទំហំ៦ហិកតា ស្ថិតនៅក្នុងកន្លែងសហគមន៍នេសាទភូមិថ្មី។ កន្លែងអភិរក្សជលផលនេះ ត្រូវបានរៀបចំ និងគ្រប់គ្រងដោយសហគមន៍នេសាទ។

**ឃ. ធនធានជលផល**

ធនធានជលផលដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង និងសេដ្ឋកិច្ច ហើយធនធានជលផលបានផ្តល់ជាអាហារនិងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ សហគមន៍នេសាទភូមិថ្មី បានឱ្យដឹងថា បច្ចុប្បន្នធនធានជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុ និងសកម្មភាពមនុស្ស។

**ប្រភេទត្រីសមុទ្រ ៖** ត្រីក្បក ត្រីក្អុក ត្រីស្លុង ត្រីក្រហម ត្រីផ្ទោង ត្រីឆ្លាម ត្រីបបែល ត្រីការ៉ាវ ត្រីប្រម៉ា ត្រីកាឡាំង ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីតុកកែ ត្រីអណ្តាតឆ្កែ ត្រីម្រេច ត្រីបាឃើ ត្រីអង្រៃ ត្រីទក់សមុទ្រ ត្រីប្លាធូ ត្រីអាំងកើយ ត្រីសេះ ត្រីសេក។ល។

**ប្រភេទវារីសត្វសមុទ្រ ៖** បង្គា បង្កង បង្កងកណ្តូប បង្កងប៉ាក ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមប្រង់ មឹកគ្រែងឈាម ងាវ ងាវភក់ ងាវហូល ងាវស អណ្តើក កន្ទាយ បាលង្កកាស កញ្ចុះ អន្ទង់ ខ្ចឹង ផ្សោតស ផ្សោតខ្មៅ ។ល។

**ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ៖** ដើមកោងកាង ក្រញឹប អម្ពូ អម្ពា ក្របាញញី ក្របាញឈ្មោល ប៉ឹង ប្រាសាក់ ដើមបើស ឈើជ័រ ដើមក្លាយ អញ្ចរ ដើមឡេវអាវ ចាក ប្រង់ ដើមដូងទឹក ផ្កាថ្ម ស្មៅសមុទ្រ ។ល។

## ៤. ការធ្វើនេសាទ

**ក. អ្នកនេសាទ ៖**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១១០នាក់ ស្រី៣១នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍៤៥នាក់ ស្រី១៤នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១៥០នាក់ ក្នុងមួយឆ្នាំ។

**ខ. ឧបករណ៍**នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| **ប្រភេទ ឧបករណ៍** | **ឯកតា** | **ចំនួន គ្រួសារ** | **ចំនួន ឧបករណ៍នេសាទ** | **ទំហំ/ប្រវែង** | **រដូវនេសាទ** |
|---|---|---|---|---|---|
| មងត្រី | ម៉ែត្រ | ៣៥ | ៥០០ម៉ែត្រ/គ្រួសារ | ៣,៥ស.មx៥០០ម | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ៧ | ៥០០ម៉ែត្រ/គ្រួសារ | ៣,៨ស.មx៥០០ម | ពីខែឧសភា ដល់ខែកញ្ញា |
| សន្ទូចមឹក | ផ្លែ | ២០ | ១០០០ផ្លែ/គ្រួសារ | លេខ១២ | ពីខែវិច្ឆិកាដល់ខែមេសា |
| សន្ទូចរនង | ផ្លែ | ១ | ៥០០ផ្លែ/គ្រួសារ | លេខ១២-១៦ | ពីខែមេសា ដល់ខែវិច្ឆិកា |
| ឈិបរុញដៃ | គ្រឿង | ១ | ១គ្រឿង/គ្រួសារ | - | ពេញមួយឆ្នាំ |
| លបក្តាម | លប | ៥ | ៥០០គ្រឿង/គ្រួសារ | - | ពេញមួយឆ្នាំ |
| លបត្រី | លប | ១ | ១៥លប/គ្រួសារ | - | ពីខែមិថុនា ដល់ខែកញ្ញា |
| រាវបង្គា | នាក់ | ១០នាក់ | - | - | ពេលទឹកនាច |
| ឈ្នាង | គ្រឿង | ៥០ | ៥០គ្រឿង | - | ពេញមួយឆ្នាំ |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៩៥គ្រឿង | ៧០០-១០០០គីឡូក្រាម | ៦-១៣ សេះ |
| ទូកអ៊ុំ ឬចែវ | ៨គ្រឿង | ៧០-១០០គីឡូក្រាម | - |

**ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖**

| ឧបករណ៍នេសាទ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រី | ម៉ែត្រ | ២០ | ៩០ម៉ែត្រ/គ្រួសារ | ៤ដៃ(១ដៃ=៦០ម) | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ១៥ | ១៨០ម៉ែត្រ/គ្រួសារ | ៤ដៃ(១ដៃ=៦០ម) | ពីខែឧសភាដល់ខែកញ្ញា |
| លបក្តាម | លប | ៥ | ៥០០គ្រឿង/គ្រួសារ | - | ពេញមួយឆ្នាំ |
| រនងខ្សង | ផ្លែ | ២ | ១៥០ម៉ែត្រ/គ្រួសារ | - | ពីខែមេសា ដល់ខែកញ្ញា |
| ឈិបរុញដៃ | គ្រឿង | ១ | ១គ្រឿង/គ្រួសារ | - | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ខ្សែ | ៣០ | ៥០០ផ្លែ/គ្រួសារ | ២ខ្សែ=ផ្លែលេខ១២ | ពីខែវិច្ឆិកាដល់ខែមេសា |
| ឈ្នាង | គ្រឿង | ៣០ | ៣០នាក់ | - | ពេញមួយឆ្នាំ |

(ម = ម៉ែត្រ)

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៤០ គ្រឿង | ៤០០គីឡូក្រាម | ៦-១៣ សេះ |
| ទូកអ៊ុំ ឬចែវ | ១៥គ្រឿង | ៧០-១០០គីឡូក្រាម | - |

**ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួននាក់ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងក្តាម | ម៉ែត្រ | ២៥ | ៥០០ម៉ែត្រ/គ្រួសារ | ៤ដៃ(១ដៃ=៦០ម) | វិច្ឆិកាដល់មករា |
| លបក្តាម | លប | ២២ | ៣០០-៥០០លប/គ្រួសារ | - | តុលាដល់មេសា |
| លបត្រី | ម៉ែត្រ | ៥ | ២៥០លប/គ្រួសារ | - | ពេញរដូវនេសាទ |
| លូកក្តាមថ្ម ក្តាមជ័រ | នាក់ | ១៥ | ១-២នាក់/គ្រួសារ | - | វិច្ឆិកាដល់មករា |
| ឈិបរុញដៃ | គ្រឿង | ៣០ | ១-២គ្រឿង/គ្រួសារ | - | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៥ គ្រឿង | ៤០០ គីឡូក្រាម | ៤,៥-៦ សេះ |
| ទូកចែវ | ២០ គ្រឿង | ៧០-១០០គីឡូក្រាម | - |

**គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ១៩៧៩ គីឡូក្រាម | ១៧៤៥ គីឡូក្រាម | ៣៧២៤ គីឡូក្រាម |
| បង្គា | ១២៣៤ គីឡូក្រាម | ១១២១ គីឡូក្រាម | ២៣៥៥ គីឡូក្រាម |
| ក្តាម | ៩១៣ គីឡូក្រាម | ៨០៥ គីឡូក្រាម | ១៧១៨ គីឡូក្រាម |
| មឹក ខ្យង និងគ្រែង ឈាម | ៩៦៨ គីឡូក្រាម | ៨៧៩ គីឡូក្រាម | ១៨៤៧ គីឡូក្រាម |
| សរុប | ៥០៩៤ គីឡូក្រាម | ៤៥៥០ គីឡូក្រាម | ៩៦៤៤ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទភូមិថ្មី មានទស្សនៈវិស័យចូលរួមអភិរក្សគ្រប់គ្រងធនធានជលផលសមុទ្រប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណង

- ចូលរួមថែរក្សា អភិរក្ស គ្រប់គ្រងដែននេសាទសមុទ្រ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទ ជាប្រពៃណីឬសហគមន៍ធ្វើនេសាទកន្លែងនេសាទសហគមន៍ នាទីព្រៃកោងកាងនិងនាទីទឹកជោរនាច
- ចូលរួមថែរក្សាការពារ ធនធានជលផលប្រកបដោយនិរន្តរភាព និងទទួលផលប្រយោជន៍ពីធនធានជលផលជាមួយប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ
- បំផុសគំនិតឱ្យកាន់តែស្រលាញ់ធនធានធម្មជាតិដោយមានការចូលរួមពីសមាជិកសហគមន៍នេសាទ និងយកចិត្តទុកដាក់ការពារឱ្យស្ថិតស្ថេរគង់វង្ស។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ផ្នែកទី១. ការអភិបាលកិច្ចនិងការគ្រប់គ្រង

#### គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

សាងសង់ស្នាក់ការសហគមន៍នេសាទ នៅចំណុចជាប់ស្នាក់ការសហគមន៍នេសាទចាស់ក្បែរផ្លូវ ចំណុចនិយាមកា ៤២២០២១ - ១១៦២២៥៧, ៤២២០២២ - ១១៦២២៤៦៥ ស្ថិតក្នុងភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាព និងអ្នកពាក់ព័ន្ធ | -មានការចូលរួម<br>-មានការគាំទ្រ | ៥០០ | សហគមន៍នេសាទ អាជ្ញាធរនិង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | មករា ២០២៦ | មិថុនា ២០២៨ |
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨មx១៣ម និងម្ខាងសម្រាប់ផ្នែករដ្ឋបាលជលផលទំហំ៦មx៩ម ធ្វើពីបេតុង រួមផ្សំ គ្រឿងឈើ ប្រក់ក្បឿង បន្ទប់មួយជ្រុង រៀបជញ្ជាំងឥដ្ឋ និង មានបង្គន់អនាម័យ | -ស.ន មានកន្លែងធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍ | ៥០ ០០០ | | មករា ២០២៦ | មិថុនា ២០២៨ |
| ភ្ជាប់បណ្តាញ និងរៀបចំអគ្គីសនី | មានថាមពលអគ្គីសនីធ្វើការ | ១ ៥០០ | | មករា ២០២៦ | មិថុនា ២០២៨ |
| រៀបចំតបណ្តាញប្រព័ន្ធទឹកស្អាត(សំណើស្នើសុំទៅអាជ្ញាធរដើម្បីអន្តរាគម | មានទឹកស្អាតប្រើប្រាស់ | ១ ២០០ | | | |

### គ២- ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី១នៃខែ រៀងរាល់ខែឬត្រីមាស | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត | ៦៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ចូលរួមប្រជុំជាមួយអាជ្ញាធរសង្កាត់ ក្រុង ឬស្ថាប័នពាក់ព័ន្ធ | -ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលការងារ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍សង្កាត់ | ៥៤០ | -អាជ្ញាធរសង្កត់<br>-គណៈកម្មការ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ចុះអនុវត្តន៍សកម្មភាពជម្រុញការចុះបញ្ជីទូកម៉ាស៊ីន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និង ជំនាញពាក់ព័ន្ធ ជាប្រចាំ | - ចុះបញ្ជីទូកម៉ាស៊ីនគ្រប់ចំនួន<br>- ទូកម៉ាស៊ីនធ្វើនេសាទបានដាក់ប្រព័ន្ធតាមដាន<br>-បទល្មើសនេសាទថយចុះ | ៦០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | -មានព័ត៌មានច្បាស់លាស់<br>-រៀបចំផែនការបានត្រឹមត្រូវ<br>-ការគ្រប់គ្រងស.នបានល្អ | ៩០០ | -គណៈកម្មការ<br>-សមាជិកស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| សម្ភារការិយាល័យ<br>- LCD with Screen<br>- ភ្ជាប់ប្រព័ន្ធWifi<br>-ទិញក្រដាស់ ប៊ិច<br>-ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ២ ០០០ | គណៈកម្មការ | កក្កដា ២០២៥ | មិថុនា ២០២៨ |

(ស.ន = សហគមន៍នេសាទ)

### គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពី ៖<br>-ច្បាប់ជលផល ច្បាប់សហគមន៍កសិកម្ម ឯកសារគតិ យុត្តិនានា | -សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ | ២ ៥៨០ | គណៈកម្មការ, សមាជិកស.ន និងអ្នកក្រៅស.ន | មករា-មិថុនា/ រៀងរាល់ឆ្នាំ | |

| | | | | | |
|---|---|---|---|---|---|
| ពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងស.ន<br>ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងបទពិសោធន៍នានាដែលទទួលបាន | ប្រមាណ៥០ភាគរយ<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ | | អាជ្ញាធរមូលដ្ឋានជំនាញជលផល, អង្គការដៃគូ | កក្កដា ២០២៥ | មីនា ២០២៨ |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-កំណត់ហេតុ<br>-របាយការណ៍<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកា និងការគ្រប់គ្រងថវិកាសហគមន៍នេសាទ | គណៈកម្មការ យុវជន និងស្ត្រីនៃសហគមន៍នេសាទ បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១ ៤០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | កក្កដា ២០២៥ | មីនា ២០២៨ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ ២នាក់ | ៣៦០ | គណៈកម្មការស.ន | កក្កដា ២០២៥ | មីនា ២០២៨ |
| វគ្គបណ្តុះបណ្តាលវិធីសាស្រ្តការប្រមូលព័ត៌មាន ដោយការកត់ត្រា ទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | គណៈកម្មការសហគមន៍នេសាទប្រមាណ៨០ភាគរយបានយល់ដឹង និងអាចយកទៅអនុវត្តន៍ក្នុងការងារជាក់ស្តែង | ៨០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | | |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់ | គណៈសហគមន៍នេសាទ ប្រមាណ១១នាក់ បានយល់ដឹងពីការដោះស្រាយទំនាស់ និងអាចអនុវត្តន៍បាន | ៤០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | កក្កដា ២០២៥ | មីនា ២០២៨ |
| បណ្តុះបណ្តាលពីសហគ្រិនភាពដល់គណៈការនិងសមាជិកស.ន | គណៈកម្មការ និងស្ត្រីមានមានការយល់ដឹងពីសហគ្រិនភាពប្រមាណ ២០ភាគរយ និងអាចអនុវត្តន៍ក្នុងសកម្មភាពសេដ្ឋកិច្ច និងអាជីវកម្ម | ៥០០ | | កក្កដា ២០២៥ | មីនា ២០២៨ |

(ស.ន = សហគមន៍នេសាទ)

### គ.៤ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| **ឈ្មោះ/ទីតាំងកន្លែងនេសាទ** | **ពេលវេលាធ្វើនេសាទ** | **ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ** | | | **ផ្សេង** |
|---|---|---|---|---|---|
| | | **ប្រភេទ** | **ទំហំ/ប្រវែង** | **ចំនួន** | |
| កន្លែងនេសាទសហគមន៍ភូមិថ្មី (គណៈកម្មការ | ពេញរដូវនេសាទ | មងត្រីក្បក | ៣០០ម | ៨០ | ក្រឡាចាប់ពី៣,៥ ស.ម |
| | | មងត្រីកាវ៉ាវ | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី៧ ស.ម |
| | | មងត្រីផ្ទោង | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី២,៥ ស.ម |

| | | | | | |
|---|---|---|---|---|---|
| និងសមាជិកសហគមន៍នេសាទ) | | មងបង្គា | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី៣,៥ ស.ម |
| | | មងក្ដាម | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី៦ ស.ម |
| | | មងបេកា | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី៨ ស.ម |
| | | មងត្រីកាម៉ុង | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី៤ ស.ម |
| | | មងត្រីគូន | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី៣ ស.ម |
| | | មងត្រីឆ្លុង | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី៧ ស.ម |
| | | មងត្រីកាតាំង | ៣០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី៦ ស.ម |
| | | មងត្រីកុង | ២០០ម/គ្រួសារ | មិនកំណត់ | ក្រឡាចាប់ពី២,៥ ស.ម |
| | | មងហ៊ុម | ៦០ម/គ្រួសារ | មិនកំណត់ | ក្រឡា៣ ស.ម |
| | | សន្ទូចរនង | ៥០០ផ្លែ/គ្រួសារ | មិនកំណត់ | |
| | | សន្ទូចដៃ | មិនកំណត់ | មិនកំណត់ | |
| | | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | | សន្ទូចបបែល | ៣០០ផ្លែ/គ្រួសារ | មិនកំណត់ | |
| | | សន្ទូចត្រីក្អក | ២០០ផ្លែ/គ្រួសារ | មិនកំណត់ | |
| | | សន្ទូចត្រីអណ្ដែងប៉ុយ | ២០០ផ្លែ/គ្រួសារ | មិនកំណត់ | |
| | | លបក្ដាមសេះ | ៣៥០លប/គ្រួសារ | មិនកំណត់ | |
| | | ឈិបរុញដៃ | មិនកំណត់ | មិនកំណត់ | |
| | | ភាវគ្រែងឈាម | មិនកំណត់ | មិនកំណត់ | |
| | | ភាវងាវភក់ | មិនកំណត់ | មិនកំណត់ | |
| | | លូកក្ដាមថ្ម ជ័រ | មិនកំណត់ | មិនកំណត់ | |
| | | សំណាញ់ | មិនកំណត់ | មិនកំណត់ | |
| | | បង្កៃត្រីទឹកសាប | មិនកំណត់ | មិនកំណត់ | |
| | | មងត្រីទឹកសាប | មិនកំណត់ | មិនកំណត់ | |
| | | លបត្រីទឹកសាប | មិនកំណត់ | មិនកំណត់ | |
| | | លាន់ | មិនកំណត់ | មិនកំណត់ | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

### គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ ឧបករណ៍នេសាទ ពេលវេលាការនេសាទត្រីកាម៉ុងនិងសារៈសំខាន់នៃធនធាន ជលផលនិងព្រំប្រទល់កន្លែងសហគមន៍នេសាទ ៖<br>-តាមឧឃោសនស័ព្ទ៣ថ្ងៃ/ឆ្នាំ<br>-បិទឯកសារ ១ដង/ឆ្នាំ<br>-ចែកឯកសារ ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ | ប្រជានេសាទយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទដែលមានចែងក្នុងផែនការគ្រប់គ្រងសហគមន៍នេសាទ និងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីជលផល ប្រមាណ ២០ ភាគរយ | ១ ៥៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កក្កដា ២០២៥ | មិថុនា ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| មករា/រៀង រាល់ឆ្នាំ | | | | | |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែ ឬឆមាស(មករានិងមិថុនា/រៀងរាល់ឆ្នាំ) | -មានរបាយការណ៍លទ្ធផលការងារ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ | ៣៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| អនុវត្តន៍ផែនការ៖ (រៀបចំកំលាំងចុះបង្រ្កាបដល់ទីកន្លែងដោយទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធនិងអង្គការដៃគូ)<br>(៤ដង/ខែ = ១៤៤/ដង) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកសហគមន៍នេសាទធូរធារ | ១០ ៣៦៨ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| មធ្យោបាយនិងសម្ភារ<br>-សាំង និងប្រេងបាត<br>-អាវ ស្បែកជើង មួកអាវភ្លៀង អាវពោង ពិលអាយកូម ម៉ាស៊ីនថត កែវយ៉ិត កាតទូរស័ព្ទ | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ៣ ៣៤៦ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ទិញទូកស្ទាច់និងម៉ាស៊ីនថ្មី ចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត ចំនួន១គ្រឿង | ២ ០០០ | | កក្កដា ២០២៥ | មិថុនា ២០២៨ |

### គ.៦ ផែនការកែលម្អកន្លែងនេសាទសហគមន៍

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| **ដែននេសាទ** | **ទំហំ** (ហិកតា) | **ទំហំដែលត្រូវកែលម្អ** | **សកម្មភាព** | **ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ភូមិថ្មី | ១៩៨ | ១៩៨ ហិកតា | ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ និងអ្នកពាក់ព័ន្ធ | ១០០ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | | | សាងសង់ផ្ទាំងប៉ាណូផ្សព្វផ្សាយ ៣ផ្ទាំង ២,៥០ ម x ២ម គ្រឿងដែក(ដែកមូល) | ៩០០ | | |
| | | | ស្លាកសញ្ញាផ្សព្វផ្សាយ ១០ផ្ទាំង១២០ស.ម x ១០០ស.ម គ្រឿងដែក(ដែកមូល) | ៧០០ | | |
| | | | កំណត់ទីតាំងតាមនិយាមកានិងបោះបង្គោលព្រំប្រទល់សហគមន៍នេសាទ ៦បង្គោល ធ្វើពីបេតុង សរសៃដែក | ៦០០ | | |
| | | | បោះពោងព្រំប្រទល់សហគមន៍នេសាទ ៦ពោង ធ្វើធុងជ័រ ខ្សែប្រវាក់ និងចាក់ស៊ីម៉ង់ | ៣០០ | | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

### គ.៧ ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំត្រូវអភិរក្ស (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អភិរក្សជលផល ៦ ហិកតា<br>421106 - 1162594<br>421366 -1162647<br>421428 -1162427<br>421175 -1162368<br> | ៦ | -ស្មៅសមុទ្រ<br>-គ្រែងឈាម<br>-ក្ដាមសេះ<br>-ត្រីផ្សោត<br>-ជីវចម្រុះ | ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផល និងហាមឃាត់ដល់ប្រជាពលរដ្ឋ ឱ្យបានទូលំទូលាយ | ៤៥០ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | | | ចុះរកទីតាំងជាក់ស្ដែងតាមនិយាមកា | ៣០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីស៊ីម៉ង់ គ្រឿងដែក (សាជី) ចំនួន៤បង្គោល | ៦ ០០០ | | |
| | | | ពង្រាយប្រអប់ជម្រកត្រីសិប្បនិម្មិតធ្វើពីបេតុងចំនួន១០០ ប្រអប់ | ៤០ ០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សជលផលភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ | ១ ០០០ | | |

### គ.៨ ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្ដាមសេះពងរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្ដាមសេះពង ត្រូវរៀបចំឡើងដើម្បីបង្កើនផលស្តុកធម្មជាតិនៃធនធានជលផល ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ | ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ភូមិថ្មី | ១០០មx១០០ម<br>សាកល្បងជំហានទី១ទំហំ ២៥មx២៥ម | -ក្ដាមសេះ<br>-ស្មៅសមុទ្រ<br>-ជីវចម្រុះ | ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយដើម្បីប្រមូលក្ដាមសេះពង | ៣៦០ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | | | ជួសជុលស្ថានីយ៍១កន្លែងនិងស្ពានដើរជុំវិញស្ថានីយ៍ធ្វើពីឈើ និងសម្ភារជាង | ១ ៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងការពារក្ដាមសេះ និងព័ទ្ធស្បៃមុង | ៥០០ | | |
| | | | ពង្រាយប្រអប់ថ្មបេតុងត្រីសិប្បនិម្មិតធ្វើពី ចំនួន១០ប្រអប់ថ្មបេតុង | ៤ ០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ២០០ | | |
| | | | ព្រលែងកូនក្ដាម និងមេក្ដាមពង | ៥០០ | | |
| | | | ទិញឧបករណ៍សម្ភារគាំទ្រសកម្មភាពភ្ញាស់កូនក្ដាមសេះ | ៥០០ | | |
| | | | ថែទាំ និងប្រមូលផល | ១០០ | | |

(ម = ម៉ែត្រ)

## គ.៩ ផែនការគ្រប់គ្រងព្រៃកោងកាង

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| ព្រៃកោងកាងដែលមានស្រាប់ក្នុងកន្លែងសហគមន៍នេសាទ | ១០ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | បោះបង្គោលព្រំព្រៃកោងកាង ធ្វើពីបេតុង ២០ស.ម x ២០ស.ម x ១,៥ម ចំនួន២០ ដោយសរសេរអក្សរ ព្រំប្រទល់ព្រៃកោងកាងសហគមន៍នេសាទភូមិថ្មី | | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាស្តីពីផែនទីព្រៃកោងកាង ២ ស្លាក ២ម x ១,៥ម ធ្វើពីគ្រឿងដែកសរសរដែកមូលក្រាស់ ចាក់បេតុង | | ៨០០ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | | | ថែរក្សា ការពារ | | | | |
| វាលភក់ស្ថិតក្នុងកន្លែងនេសាទសហគមន៍ ១០ ហិកតា | ១០ | កោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងជាក់ស្តែងតាមនិយាមកា | | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាស្តីពីផែនទីព្រៃកោងកាង ២ ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែកចាក់បេតុង | | ៨០០ | | |
| | | | រៀបចំថ្នាលបណ្តុះកូនកោងកាងបង្គោលឈើ និងស្បៃ ៥០ម x ៥០ម | | ៤ ០០០ | | |
| | | | បណ្តុះកូនដកោងកាង ចំនួន ៧០ ០០០ដើម(១ហិកតាx៧០០០ដើម) | | ៧០ ០០០ | | |
| | | | ដាំកូនកោងកាងចំនួន ១៥នាក់x៨,៥ដុល្លារ/ថ្ងៃ | | ៤ ៤៦៣ | | |
| | | | ថែទាំដើមកោងកាង ៤នាក់ x ១០ដុល្លារ/ថ្ងៃ,២ថ្ងៃ/អាទិត្យ រយៈពេល៣ខែ | | ១ ០០០ | | |
| | | | ៤នាក់ x ១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/អាទិត្យ ពី៣ខែដល់៦ខែ | | ១ ០០០ | | |
| | | | ៤នាក់ x ១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/ខែ ពី៦ខែឡើងទៅរហូតដល់៣ឆ្នាំ | | ១ ២០០ | | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

**ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ**

**គ១០- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ**

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹមគ្រែងឈាម | គណៈកម្មការប្រមាណ៥០ភាគរយ និងក្រុមមុខរបរ ៧០ភាគរយ ៖<br>-មានចំណេះដឹងក្នុងការចិញ្ចឹម<br>-យកទៅអនុវត្តជាក់ស្តែងបាន<br>- សមាជិកនិងគណៈកម្មការស.ន ទទួលបានចំណេះដឹងលើគុណភាពទឹក តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជាតិពុលក្នុងទឹក ការពិនិត្យគុណភាពទឹក ការតាមដាន និងរាយការណ៍<br>-ការអនុវត្តសាកល្បងលើការចិញ្ចឹមដោយមិនប្រើចំណី។ | ៩០០ | គណៈកម្មការនិង សមាជិកស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ចិញ្ចឹមក្តាមថ្ម ក្តាមសេះ | | ៩០០ | គណៈកម្មការនិង សមាជិកស.ន | | |
| ចិញ្ចឹមខ្យងចំពុះទា | | ៩០០ | គណៈកម្មការនិង សមាជិកស.ន | | |
| ចិញ្ចឹម(ត្រីឆ្តង់ កង្កែប អន្ទង់) | | | | កក្កដា ២០២៥ | មិថុនា ២០២៨ |
| កែច្នៃផលនេសាទ | ក្រុមមុខរបរ ៧០ភាគរយ<br>-មានចំណេះដឹង<br>-មានសុវត្ថិភាពចំណីអាហារ<br>-មានជម្រើសមុខរបរ<br>-បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិង សមាជិកស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | | ៩០០ | | | |
| បច្ចេកទេសដាំបន្លែ | | ៩០០ | | | |
| បច្ចេកទេសកសិកម្មចម្រុះ និងកសិកម្មបន្ត | | ៩០០ | | | |
| ២.ទស្សនៈកិច្ចសិក្សា | គណៈកម្មការ៨០ភាគរយ មានបទពិសោធន៍ពីសហគមន៍ ទទួលបានជោគជ័យ និងយកមកអនុវត្ត | ២ ៥០០ | គណៈកម្មការនិង សមាជិស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ៣.ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមចិញ្ចឹមគ្រែងឈាម | -មានក្រុម មុខរបរចំនួន៣ក្រុម ត្រូវបានបង្កើត ដោយផ្តោតលើការចិញ្ចឹមគ្រែងឈាម ក្តាមថ្ម ក្តាមសេះ និងងាវភក់ គ្រុំចំពុះទា<br>-មានគ្រែងឈាម តាមថ្ម និងងាវភក់ផ្គត់ផ្គង់ទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិង សមាជិស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ក្រុមចិញ្ចឹមក្តាមថ្ម ក្តាមសេះ | | | | | |
| ក្រុមចិញ្ចឹមគ្រុំចំពុះទា | | | | | |
| ក្រុមចិញ្ចឹមត្រីឆ្តង់ | -មានក្រុមចិ.ត្រីឆ្តង់<br>-មានត្រីឆ្តង់ផ្គត់ផ្គង់ដល់កន្លែង | ៥០០ | គណៈកម្មការនិង សមាជិស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| | ទេសចរណ៍និងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | | | | |
| ក្រុមចិញ្ចឹមកង្កែប និងអន្ទង់ | -មានក្រុមចិញ្ចឹមកង្កែប អន្ទង់<br>-មានកង្កែប អន្ទង់ផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ក្រុមកែច្នៃផលនេសាទដោយផ្តោតលើ ៖<br>-ក្រុមស្ត្រី<br>-ជនងាយរងគ្រោះក្នុងស.ន | -មានក្រុមកែច្នៃផលនេសាទ<br>-មានផលិតផលជលផលផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ក្រុមដាំបន្លែ | -មានក្រុមដាំបន្លែ<br>-មានបន្លែផ្គត់ផ្គង់តម្រូវការ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ក្រុមកសិកម្មចម្រុះ និងកសិកម្មបន្ត | -មានក្រុមកសិកម្មចម្រុះនិងបន្ត<br>-មានដំណាំចម្រុះផ្គត់ផ្គង់តម្រូវការ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |
| ក្រុមបណ្តុះកូនកោងកាងដើម្បីផ្គត់ផ្គង់ដល់សប្បុរសជន សកម្មភាពទេសចរណ៍ និងទីផ្សារ | -បណ្តុះកូនកោងកាងលើថ្នាលទំហំ ២០ម x ២០ម<br>-ដើម្បីផ្គត់ផ្គង់ដល់សប្បុរសជននិងសកម្មភាពទេសចរណ៍ចំនួន ៣០ ០០០ដើម | ៣ ០០០ | គណៈកម្មការនិងសមាជិស.ន | កក្កដា ២០២៥ | មិថុនា ២០២៨ |

(ស.ន = សហគមន៍នេសាទ)

**គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ**

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមកង្កែប អន្ទង់តាមអាង ឬតង់ (១៥គ្រួសារ) | ២តង់x២មx១,៥មx១,២ម | អន្ទង់ | ១៣ ៥០០ | ១ ៦២៥ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | ២តង់x២មx១,៥មx១,២ម | កង្កែប | ១៣ ៥០០ | ១ ៦២៥ | | |
| | សាងសង់អាង ឬទិញតង់ | | - | ២ ៤០០ | | |
| ក្រុមចិញ្ចឹមត្រីឆ្តង់តាមបែរ២០បែរ | ២០បែរx៤មx៣មx២ម | ត្រីឆ្តុង | ២៤ ០០០ | ១៦ ៦៦០ | | |
| | សាងសង់បែរ | | - | | | |
| ចិញ្ចឹមគ្រែងឈាម ទំហំ ០,៨៦ ហិកតា 421912 1162249 421812 1162259 421769 1162352 421868 1162339 | ប្រជុំផ្សព្វផ្សាយ | គ្រែងឈាម | - | ២០០ | កក្កដា ២០២៥ | មិថុនា ២០២៨ |
| | បង្គោលឈើចម្រុះ ២០០ ដើម x ៨០០០រៀល | | - | ៤០០ | | |
| | របាំងសាច់អួន | | - | ១ ៥០០ | | |
| | កូនពូជគ្រែងឈាម | | ៥០០គ.ក | ១ ៨០០ | | |

| | | | | | | |
